www.foodfitphilly.org/food-justice

# គំនិតផ្តួចផ្តើមអំពីកម្មវិធីយុត្តិធម៌ចំណីអាហារហ្វីឡាដែលហ្វៀ (PFJI, Philadelphia Food Justice Initiative)

កម្មវិធីអាហារសុខភាពហ្វីលី (Get Healthy Philly) X មូលនិធិវិនិយោគឡើងវិញ (Reinvestment Fund)

## សន្លឹកព័ត៌មាន

## មូលនិធិឆ្នាំសារពើពន្ធ 2021 - ទី 1 ខែកក្កដា ឆ្នាំ2020 - ទី 30 ខែមិថុនា ឆ្នាំ2021

ក្នុងភាពជាដៃគូជាមួយនឹងមូលនិធិវិនិយោគឡើងវិញ (Reinvestment Fund) ផ្នែកបង្ការជម្ងឺរ៉ាំរ៉ៃ និងរបួសស្នាម នៃនាយកដ្ឋានសុខភាពសាធារណៈ ក្រុងហ្វីឡាដែលហ្វៀ (The Philadelphia Department of Public Health’s Division of Chronic Disease Prevention) ដែលត្រូវគេហៅផងដែរថា កម្មវិធីអាហារសុខភាពហ្វីលី (GHP, Get Healthy Philly) កំពុងស្វែងរកសំណើគម្រោងដែលមានការច្នៃប្រឌិតសម្រាប់អនុវត្តគម្រោងការសហគមន៍ ពាក់ព័ន្ធនឹងការផលិតស្បៀងអាហារយុត្តិធម៌ សម្រាប់ពលរដ្ឋក្រុងហ្វីឡាដែលហ្វៀទាំងអស់គ្នា ។

**មូលនិធិជំនួយ** ៖ មានទឹកប្រាក់ចំនួន $150 000 សម្រាប់ផ្តល់ជូនជាជំនួយឧបត្ថម្ភ ដែលរង់ចាំការអនុម័តពីសាលាក្រុង សម្រាប់ថវិកាឆ្នាំសារពើពន្ធ 2021 ។

**រយៈពេលគម្រោង** ៖ គម្រោងទាំងអស់ត្រូវបញ្ចប់ក្នុងរវាងថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2020 – ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2021 ដែលមានសក្តានុពលក្នុងការបន្តផ្តល់ជំនួយមូលនិធិក្រោយចប់គម្រោង ។

### បន្ទាត់ពេលវេលាការដាក់ពាក្យសុំជំនួយ ៖

1. ថ្ងៃទី 24 ខែមេសា – ពាក្យសុំជំនួយទាំងអស់ផុតកំណត់ត្រឹមម៉ោង 11:59នាទីយប់
2. ដើមខែមិថុនា – ជ្រើសរើសអ្នកត្រូវទទួលបានជំនួយ ហើយជូនដំណឹងដល់អ្នកដាក់ពាក្យសុំទាំងអស់
3. ថ្ងៃទី 1 ខែកក្កដា – គម្រោងចាប់ដំណើរការ

### របៀបដាក់ពាក្យសុំជំនួយ ៖

**Amanda Wagner** (she/her)
**ប្រធានគម្រោង អាហារូបត្ថម្ភ និងសកម្មភាពរូបវន្ត** (Program Manager, Nutrition and Physical Activity)
**នាយកដ្ឋានបង្ការជំងឺរ៉ាំរ៉ៃ និងរបួសស្នាម** (Division of Chronic Disease and Injury Prevention)
**នាយកដ្ឋានសុខភាពសាធារណៈក្រុងហ្វីឡាដែលហ្វៀ** (Philadelphia Department of Public Health)
o: 215.685.5252
e: amanda.wagner@phila.gov

### នរណាខ្លះអាចដាក់សំណើគម្រោងបាន

**ការអំពាវនាវរកគំនិតដោយបើកចំហនេះ គឺសម្រាប់ពលរដ្ឋទូទៅ ។ សូមផ្ញើឲ្យយើងខ្ញុំនូវគំនិតច្នៃប្រឌិតរបស់អ្នក និងយុទ្ធសាស្ត្រយុត្តិធម៌ចំណីអាហារដែលអាចពង្រីកបាន ដែលអាចលូតលាស់ដោយមានការគាំទ្រ ។**

អ្នកដាក់ស្នើគម្រោងត្រូវរស់នៅក្នុងក្រុងហ្វីឡាដែលហ្វៀ ហើយអាចស្នើសុំថវិកាសម្រាប់គម្រោងមានចំនួនទឹកប្រាក់រហូតដល់ $150 000 ។ អង្គការមិនរកកម្រៃ អាជីវកម្មរកកម្រៃ សហករណ៍ ឬក្រុមធ្វើការរួមគ្នាដើម្បីយុត្តិធម៌ចំណីអាហារ មានសិទ្ធិដាក់ពាក្យសុំជំនួយថវិកា ។ អាជីវកម្មផ្នែកលក់អាហាររាយ ឬដុំ មានសិទ្ធិដាក់ពាក្យសុំជំនួយថវិកា ។ សម្រាប់អាជីវកម្មលក់រាយ អ្នកដាក់ស្នើគម្រោង ត្រូវប្តេជ្ញាមិនលក់ផលិតផលពាក់ព័ន្ធនឹងថ្នាំជក់ ។

យើងខ្ញុំស្វាគមន៍គំនិត និងគម្រោងពីអ្នកដាក់សំណើទាំងអស់ ដែលមានបំណងកសាងយុត្តិធម៌ចំណីអាហារនៅទីក្រុងហ្វីឡាដែលហ្វៀ ដោយមានបញ្ចូលចក្ខុវិស័យយុត្តិធម៌សុខភាព ។ បើអ្នកបាននិងកំពុងធ្វើការផ្នែកជួយឲ្យសហគមន៍ទទួលបានស្បៀងអាហារអស់រយៈពេលជាយូរកន្លងមក ហើយ

អ្នកត្រូវការជំនួយជ្រោមជ្រែងមួយចំនួន ដើម្បីពង្រីកសកម្មភាព និងឈានមួយជំហានទៅមុខទៀត គឺយើងខ្ញុំចង់ដឹងពីគំនិតរបស់លោកអ្នក ។ បើលោកអ្នកជាអង្គការប្រចាំមូលដ្ឋាន និងធ្វើការផ្នែកកសាងសមត្ថភាព ហើយមានវិធីច្បាស់លាស់ ក្នុងការបញ្ចូលអាហារទ្រទ្រង់សុខភាព ក្នុងផែនការរបស់ខ្លួន យើងខ្ញុំក៏ចង់ដឹងពីគំនិតរបស់លោកអ្នកដែរ ។ បើលោកអ្នកជាសហគ្រិនថ្មី ដែលមានគនិតថ្មី យើងខ្ញុំចង់ដឹងពីគំនិតរបស់លោកអ្នក ។ បើលោកអ្នកជាអ្នកផលិត ដាំដុះ លក់ ឬបរិភោគអាហារ យើងចង់ដឹងពីគំនិតរបស់អ្នក ។

ក្នុងឆ្នាំ 2019 យើងខ្ញុំបានផ្តល់ថវិកាឧបត្ថម្ភគម្រោងដល់ប្រាំមួយ (6) អង្គការ ។ អ្នកដាក់ពាក្យសុំទាំងអស់ដែលបានដាក់ស្នើគម្រោងចំពោះគំនិតផ្តួចផ្តើមនេះកាលពីពេលមុន តែមិនទទួលបានជោគជ័យ យើងខ្ញុំសូមណែនាំឲ្យលោកអ្នកដាក់ស្នើគម្រោងជាថ្មីម្តងទៀត ។

**លក្ខណៈវិនិច្ឆ័យ និងដំណើរការជ្រើសរើស**
គម្រោងទាំងអស់ គួរតែផ្តោតចំពោះការបង្កើនភាពទទួលបានអាហារសុខភាព (សូមអាននិយមន័យ) នៅក្នុងតំបន់ក្បែរខាង ឬសហគមន៍ ដែលមានប្រវត្តិជួបបញ្ហាអយុត្តិធម៌ចំណីអាហារ ។ គម្រោងនីមួយៗត្រូវរួមបញ្ចូល យ៉ាងហោចណាស់ចំណុចណាមួយ ខាងក្រោម ៖ 1) ចាក់ឫសយ៉ាងជ្រៅនៅក្នុងតំបន់ក្បែរខាង ឬ សហគមន៍ (ដែលបានកំណត់) 2) គ្របដណ្តប់ទូទាំងក្រុង ឬ 2) សក្តានុពលចំពោះការផ្លាស់ប្តូរប្រព័ន្ធ ឬការពង្រីកសកម្មភាពជាបន្តបន្ទាប់ ។

អាទិភាពនឹងត្រូវផ្តល់ជូនដល់គម្រោងទាំងឡាយណាដែល 1) ដឹកនាំដោយមនុស្សដែលមិនមែនសម្បុរស និង/ឬអ្នកដែលធ្លាប់ជួបបទពិសោធន៍ជីវិតផ្នែកអយុត្តិធម៌សុខភាព និង 2) ដែលមានភាពជាកម្មសិទ្ធិសហគមន៍ពិតប្រាកដ ។ ចំណុចគន្លឹះ គឺមានការផ្តល់សំណងសមរម្យដល់បុគ្គលិក និងអង្គភាពដៃគូ ។

គណៈកម្មការជ្រើសរើសគម្រោង នឹងប្រជុំគ្នាពិនិត្យមើលសំណើទាំងអស់ ហើយជ្រើសរើសអ្នកទទួលមូលនិធិឧបត្ថម្ភ ។ នាយកដ្ឋានសុខភាពសាធារណៈ (Department of Public Health) សូមរក្សាសិទ្ធិដើម្បីជ្រើសរើសបេក្ខភាពតែមួយ ឬច្រើននាក់ តាមសមត្ថភាពក្នុងការផ្តល់មូលនិធិជ្រោមជ្រែង ដែលអាស្រ័យលើស្ថានភាពរបស់សំណើសុំ ។ ថវិកាឧបត្ថម្ភទាំងអស់ គឺអាស្រ័យលើការអនុម័តថវិកាសម្រាប់ថ្នាំសារពើពន្ធឆ្នាំ 2021 របស់សាលាក្រុង ។

ចំពោះសំណើសុំណាដែលមិនបានជ្រើសរើស យើងខ្ញុំនឹងរក្សាទុកសម្រាប់ការជ្រើសរើសនាពេលអនាគត ឬក៏ពិនិត្យដើម្បីស្វែងរកឱកាសទទួលបានមូលនិធិជ្រោមជ្រែងផ្សេងទៀត ដែលអាចមានភាពសមរម្យចំពោះស្ថានភាពនៃគម្រោងទាំងអស់នោះ ។ ឧទាហរណ៍ ចំពោះអ្នកដាក់ស្នើគម្រោងអាជីវកម្មអាហាសុខភាព គឺយើងខ្ញុំអាចបញ្ជូនសំណើនេះទៅកាន់នាយកដ្ឋានពាណិជ្ជកម្ម (Commerce Department) ដើម្បីឲ្យពួកគាត់ពិនិត្យមើលថាតើ សំណើបែបនេះ មានភាពត្រូវគ្នាចំពោះកម្មវិធីជំនួយហិរញ្ញវត្ថុ ឬជំនួយបច្ចេកទេស ដែលមានស្រាប់ដែរឬទេ ។

សំណើទាំងអស់ដែលបានជ្រើសរើសសម្រាប់ផ្តល់ថវិកាឧបត្ថម្ភ នឹងទទួលបានសេចក្តីជូនដំណឹងដែលមានព័ត៌មានលំអិត ពាក់ព័ន្ធកិច្ចព្រមព្រៀង និងលក្ខខ័ណ្ឌ នៃការទទួលថវិកាឧបត្ថម្ភ ។ គម្រោងគំនិតផ្តួចផ្តើមអំពីយុត្តិធម៌ចំណីអាហារហ្វីឡាដែលហ្វៀ (Philadelphia Food Justice Initiative) គឺជាកម្មវិធីដែលគ្រប់គ្រងដោយមូលនិធិវិនិយោគឡើងវិញ (Reinvestment Fund) ដែលជាវិទ្យាស្ថានហិរញ្ញវត្ថុអន្តការីមិនរកកម្រៃផ្នែកអភិវឌ្ឍន៍សហគមន៍ ។

**និយមន័យ ៖**

1. **យុត្តិធម៌សុខភាព** ៖ ចលនារួមដើម្បីព្យាបាលសង្គម និងលុបបំបាត់ឧបសគ្គដែលរារាំងបុគ្គល និងសហគមន៍ពីការរស់នៅប្រកបដោយសុខុមាលភាព ។ យើងខ្ញុំជម្រុញឲ្យមានយុត្តិធម៌សុខភាព ដោយការតស៊ូចំពោះប្រព័ន្ធដែលបង្កឲ្យមានភាពមិនស្មើគ្នាចំពោះសមិទ្ធិផលសុខភាព ដោយផ្អែកលើរចនាសម្ព័ន្ធពូជសាសន៍ សង្គម និងសេដ្ឋកិច្ច ។ លទ្ធផលទទួលបានពីកិច្ចខិតខំប្រឹងប្រែងនេះ គឺជាសង្គមមួយ ដែល បុគ្គលគ្រប់រូប និងសហគមន៍ ទទួលបានធនធាន និងឱកាសប្រកបដោយសមធម៌សម្រាប់ការរស់បានយូរ ប្រកបដោយភាពរីករាយ និងមានសុខភាពល្អ ។ សូមអានព័ត៌មានបន្ថែមនៅទីនេះ ៖ http://foodfitphilly.org/health-justice-summit-2018/

2. **យុត្តិធម៌អាហារ ៖** សហគមន៍អាចប្រើសិទ្ធិរបស់ខ្លួនក្នុងការដាំដុះ លក់ និងទទួលទានអាហារទ្រទ្រង់សុខភាព (ពីយុត្តិធម៌អាហារ- JustFood)
3. **អាហារសុខភាព ៖** អាហារសម្រាប់កសាង និងទ្រទ្រង់សុខភាពមនុស្ស ដូចជា ៖ ផ្លែឈើ និងបន្លែស្រស់ គ្រាប់ធញ្ញជាតិនៅទាំងមូល គ្រាប់សណ្តែក (Beans) គ្រាប់សណ្តែក (peas) គ្រាប់សណ្តែក (lentils) និងគ្រាប់សណ្តែកផ្សេងៗទៀត គ្រាប់ផ្លែឈើសំបករឹង (Nuts) និងគ្រាប់រុក្ខជាតិសំបករឹងតិចតួច (seeds) អាហារប្រភេទប្រូតេអ៊ីន ដូចជាត្រី តៅហ៊ូ និងផលិតផលទឹកដោះគោស្រស់ដែលមានជាតិខ្លាញ់ទាប ។ ជាលក្ខណៈរួម អាហារទ្រទ្រង់សុខភាព គឺជាអាហារស្រស់ ឬអាហារកករឹង ដែលមិនមានការលាយជាតិស្ករ ខ្លាញ់ ឬការដាក់អំបិលបន្ថែមឲ្យប្រៃខ្លាំង ។ នៅក្នុងចំណុចនេះដែរ អ្វីដែលមានអាទិភាពគឺជាប្រភេទអាហារដែលដាំដុះ រៀបចំ និងចែកចាយ ក្នុងលក្ខណៈមិនបង្កផលប៉ះពាល់ដល់សុខភាពកម្មករ បរិស្ថាន និងសុខភាពសត្វ ។
4. **ពាណិជ្ជកម្មអាហារសុខភាព ៖** មុខរបរលក់អាហាររាយ ឬអាជីវកម្មអាហារដ្ឋានដូចជាទីផ្សារផលិតផល ហាងកាហ្វេ ឬហាងនានា ដែលលក់អាហាររៀបចំរួច និងអាហារកញ្ចប់សម្រាប់សុខភាព ដែលមានភាពសមស្របទៅតាមនិយមន័យខាងលើនៃ "អាហារសុខភាព" ។ ក្នុងនេះផងដែរ សូមអាននិយមន័យទូលំទូលាយនៃពាក្យ "អាជីវកម្មអាហារល្អ" ដែលមានរៀបរាប់នៅក្នុងរបាយការណ៍ ការបរិភោគត្រឹមត្រូវ (Good Eats) [1]។

**អ្វីដែលយើងដឹង ៖**
យើងដឹងថា យុត្តិធម៌អាហារ គឺជាយុត្តិធម៌សុខភាព (សូមអាននិយមន័យ) ។ តាមប្រវត្តិនៃរឿងរ៉ាវដែលបានកើតឡើងកន្លងមក ប្រព័ន្ធអាហារ បានបង្កឲ្យមានការផ្លាស់ប្តូរទីកន្លែងរស់នៅ ក្លាយជាទាសករ និងត្រូវគេឲ្យតម្លៃពលកម្មទាប បាត់បង់សិទ្ធិដីធ្លី និងការសម្រេចជោគវាសនាដោយខ្លួនឯងនៃជនស្បែកខ្មៅ និងស្បែកពណ៌ត្នោត ស្ត្រី ជនអន្តោប្រវេសន៍ និងជនជាតិដើម ។[2] សព្វថ្ងៃ នៅក្រុងហ្វីឡាដែលហ្វៀ តំបន់ក្បែរខាងដែលមានគ្រួសារមានប្រាក់ចំណូលទាបរស់នៅកកកុញ និង/ឬពលរដ្ឋដែលមិនមែនស្បែកស គឺពួកគេនៅជួបបញ្ហាដោយទទួលបានជម្រើសតិចតួចអំពីការទទួលបានអាហារស្រស់ បរិភោគ ។[3]

អង្គភាព Get Healthy Philly បានជ្រោមជ្រែងគម្រោងជាច្រើនពាក់ព័ន្ធនឹងការទទួលបានអាហារសុខភាព ក្នុងអំឡុងពេល 10 ឆ្នាំមកនេះ តែទោះជាយ៉ាងណាក៏ដោយ យើងដឹងថា បញ្ហានៅមិនទាន់បានដោះស្រាយរួចរាល់ឡើយ ។ ហើយយើងខ្ញុំដឹងថា មានក្រុមដ៏គួរឲ្យស្ញប់ស្ញែងមួយចំនួន កំពុងនាំគ្នាធ្វើការងារសំខាន់ ដើម្បីឈានទៅរកយុត្តិធម៌ចំណីអាហារ ដែលអាចទទួលបានប្រយោជន៍ពីការវិនិយោគ និងជ្រោមជ្រែងរបស់យើងខ្ញុំ ក៏ដូចជាអាចទទួលបានប្រយោជន៍ពីការផ្សារភ្ជាប់ជាមួយក្រុមផ្សេងទៀតនៅទូទាំងក្រុង ។

យើងក៏បានដឹងដែរថា ក្រុងហ្វីឡាដែលហ្វៀ មានទ្រព្យអាហារ និងឱកាសយ៉ាងច្រើន សម្រាប់សកម្មភាពបុគ្គល និងសមូហភាព ។ សូមអានអនុសាសន៍ពីរបាយការណ៍ការបរិភោគត្រឹមត្រូវ (Good Eats) ឬលទ្ធផលគិតមកដល់ថ្ងៃនេះ នៃដំណើរការរៀបចំផែនការកសិកម្មក្រុងរបស់សាលាក្រុង [4] សម្រាប់ឧទាហរណ៍ពីរ ។

ជារួម យើងខ្ញុំចង់ឃើញមានដំណោះស្រាយដែលធ្វើឡើងដើម្បីជួយដល់តម្រូវការសហគមន៍ ដើម្បីបង្កើតនូវប្រព័ន្ធស្បៀងអាហារដែលកាន់តែមានភាពយុត្តិធម៌ជាងមុន ដែលជម្រុញសហគមន៍ឲ្យដាំដុះ លក់ និងបរិភោគអាហារទ្រទ្រង់សុខភាព ។

**អ្វីដែលយើងត្រូវការ ៖**

---

[1] ការបរិភោគត្រឹមត្រូវ (Good Eats) ៖ http://economyleague.org/uploads/files/4171470634539374-goodeats-finalreport.pdf
[2] កំណត់រូបរាងចេញពីអាហាររូបករណ៍ Castanea (Castanea Fellowship)៖ https://www.castaneafellowship.org/
[3] របាយការណ៍លក់រាយតាមតំបន់ក្បែរខាង (Neighborhood Food Retail Report) ៖ http://foodfitphilly.org/neighborhoodfoodretail/
[4] ផែនការកសិកម្មក្រុងហ្វីឡាដែលហ្វៀ (Philadelphia's Urban Agriculture Plan) ៖ https://sites.google.com/view/phillyagplan

យើងខ្ញុំត្រូវការបង្កើន និងពង្រីក សមភាពចំពោះការទទួលបានអាហារទ្រទ្រង់សុខភាពដែលមានតម្លៃសមរម្យ ជាពិសេសផលិតផលអាហារ ។ យើងខ្ញុំចង់ផ្តល់ឱកាសដល់សហគមន៍ ដើម្បីផលិត លក់ ឬចែកចាយអាហារទ្រទ្រង់សុខភាព ដែលមាននិរន្តរភាព និងមានភាពសមរម្យទៅតាមវប្បធម៌ នៅក្នុងតំបន់ក្បែរខាងរបស់ពួកគេ ។ យើងខ្ញុំមានបំណងស្វែងរកសមាជិកសហគមន៍ និងអង្គការមូលដ្ឋាន ដែលអាចកំពុងតែធ្វើកិច្ចការនេះរួចទៅហើយ តែត្រូវការធនធាន ដើម្បីពង្រីក ឬបង្កើនសកម្មភាព នៅក្នុងសហគមន៍របស់ខ្លួន ។

សកម្មភាពរបស់គម្រោង អាចរួមមបញ្ចូលនូវការដាំដុះ ឬការធ្វើចំណីអាហារ (សួនច្បារដំណាំ ការជ្រោមជ្រែងអ្នកបង្កើតមុខរបរថ្មី ឬផ្ទះបាយសហគមន៍ ។ល។) ការបញ្ជូនស្បៀងអាហារ (ការទិញជាក្រុម ប្រព័ន្ធថ្មីដើម្បីបញ្ជូនអាហារ ឬដំណោះស្រាយលើប្រព័ន្ធបញ្ជូនអាហារ ។ល។) ការលក់ចំណីអាហារ (លក់រាយ) ការកាត់បន្ថយការខូចខាតចំណីអាហារ ឬការធ្វើទីផ្សារចំណីអាហារ ។

គំរូគំនិតសំណើសុំ ៖

- ការចាប់ផ្តើមផលិតកម្មអាហារថ្មី ឬកន្លែងកែច្នៃអាហារដើម្បីបន្ថែមគុណតម្លៃអាហារ ដូចជាការកែច្នៃផ្លែឈើចម្រុះដាក់កែវ
- ការបង្កើតចំណុចស្តុលសម្រាប់ផ្គត់ផ្គង់ស្បៀងអាហារក្នុងតំបន់ សម្រាប់កសិករ និងអ្នកធ្វើសួននៅទីក្រុង ដើម្បីលក់ផលិតផលអាហារ
- ការបង្កើតប្រព័ន្ធ ដើម្បីចែកចាយផលិតផលអាហារដែលផលិតលើសពីតម្រូវការដោយមិនគិតថ្លៃ
- ដំណោះស្រាយឡូជីស្ទិកផ្នែកចែកចាយស្បៀងអាហារ
- បង្កើតម៉ូដែលការទិញអាហារជាសហករណ៍ ដើម្បីបង្កើនអំណាចការទិញ សម្រាប់អ្នកមានមុខរបរខ្នាតតូច ដូចជាមជ្ឈមណ្ឌលថែទាំក្មេង
- ការពង្រីកអាជីវកម្មអាហារសុខភាពដែលមានស្រាប់ ដើម្បីអាចផ្តល់ជូនដល់អតិថិជនកាន់តែច្រើនជាងមុន ឬការរចាប់ផ្តើមអាជីវកម្មថ្មីអំពីអាហារសុខភាពនៅក្នុងតំបន់ក្បែរខាង ដែលកំពុងជួបបញ្ហាទទួលបានអាហារសុខភាព ។ តម្លៃចាប់ផ្តើមអាចរួមបញ្ចូលនូវការសិក្សាសក្តានុពល ការពិគ្រោះយោបល់អំពីអាជីវកម្ម ការចំណាយមុនការអភិវឌ្ឍន៍អាជីវកម្ម ឬដើមទុនសម្រាប់ចាប់ផ្តើម ឬសន្និធិដើមគ្រា ។
- ការបើកសហគ្រាសចែកចាយផលិតផលអាហារ ដើម្បីជួយចែកចាយផលិតផលអាហារឲ្យបានច្រើន ទៅដល់ហាងលក់រាយតូចៗ ឬអង្គការមូលដ្ឋាន ។
- វិថីសុវត្ថិភាព ទៅកាន់អាហារទ្រទ្រង់សុខភាព (ជម្រើសការដឹកជញ្ជូន ឬយុទ្ធសាស្ត្រ)

# បែបបទពាក្យស្នើសុំ

**ផ្នែកទីមួយ ៖ ព័ត៌មានអ្នកដាក់ពាក្យ**

1. ចំណងជើងគម្រោង
2. ចំនួនថវិកាស្នើសុំ (រហូតដល់ $150 000)
3. រៀបរាប់អំពីបេសកម្មរបស់ អង្គការ/ អាជីវកម្ម និងទស្សនវិស័យ របស់អ្នក (100 ពាក្យ)
4. តើសហគមន៍ ឬពលរដ្ឋបែបណាដែលចូលរួម និង/ឬដែលជាក្រុមគោលដៅរបស់គម្រោងនេះ? (100 ពាក្យ)
5. តើរចនាសម្ព័ន្ធដឹកនាំរបស់អង្គការអ្នក (នាយកប្រតិបត្តិ គណៈគ្រប់គ្រង ឬផ្សេងៗ) បង្ហាញនូវភាពចម្រុះ និងការមិនរើសអើង រួមទាំងពូជសាសន៍ យេនឌ័រ និងភាពចម្រុះនៃអាយុ ឬបទពិសោធន៍ក្នុងការរស់នៅជាមួយជនអន្តោប្រវេសន៍ ឬភាពក្រីក្រ? (100 ពាក្យ)
6. នៅក្នុងអង្គការរបស់អ្នក នរណាជាអ្នកដឹកនាំគម្រោង? នរណាជាក្រុមអនុវត្តគម្រោងនៅក្នុងអង្គការអ្នក? (100 ពាក្យ)
7. នរណាជាដៃគូគម្រោង និងតួនាទីរបស់ពួកគេ? (100 ពាក្យ)

**ផ្នែកទីពីរ ៖ ព័ត៌មានរបស់គម្រោង**

8. សេចក្ដីសង្ខេបអំពីគម្រោង ៖ តើគម្រោងរបស់អ្នកនិយាយអំពីអ្វី ហើយហេតុអ្វីបានជាត្រូវតែមានគម្រោងនេះ? តើអ្វីជាគោលបំណងគន្លឹះ ឬជាសមិទ្ធផលប្រចាំឆ្នាំ? (250 ពាក្យ)
9. លទ្ធផលគម្រោង ៖ តើគម្រោងនេះ ខុសពីអ្វីដែលអ្នកកំពុងធ្វើក្នុងពេលនេះយ៉ាងដូចម្ដេច? មួយឆ្នាំក្រោយមក តើការផ្លាស់ប្ដូរអ្វីខ្លះដែលនឹងកើតឡើង (គិតត្រឹមថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2021)? តើមានមនុស្សប៉ុន្មាននាក់នឹងទទួលផលប៉ះពាល់? (500 ពាក្យ)
10. ឥទ្ធិពលគម្រោង ៖ តើគម្រោងរបស់អ្នកអាចបង្កើនវត្តមាន/ការប្រើប្រាស់អាហារសុខភាពតាមរបៀបណា (សូមមើលនិយមន័យ)? តើគម្រោងរបស់អ្នកពាក់ព័ន្ធនឹងយុត្តិធម៌សុខភាពហ្វីឡាដែលហ្វៀដោយរបៀបណា? តើនេះជាកតាលីករ ឬការផ្លាស់ប្ដូរប្រព័ន្ធ? (500 ពាក្យ)

11. តើនេះជាគម្រោងលក់រាយមែនទេ? (សូមជ្រើសយកតែមួយ)
    a. លក់រាយ
    b. មិនមែនលក់រាយ

បើលក់រាយ ៖

i. តើនេះជាអាជីវកម្មមានស្រាប់ ឬអាជីវកម្មថ្មី?
ii. បើនេះជាអាជីវកម្មថ្មី ឬ ទីតាំងថ្មី តើអ្នកមានបំណងបង្កើតនៅទីណា?
iii. តើបច្ចុប្បន្ន អ្នកកំពុងពឹងពាក់ឈ្មួញកណ្ដាល ឬអ្នកដទៃឲ្យជួយមែនទេ?
iv. តើបច្ចុប្បន្ន អ្នកមានអាជ្ញាប័ណ្ណអាជីវកម្មដែលមានសុពលភាពដែរឬទេ?
v. សូមរៀបរាប់អំពីផែនការអាជីវកម្មជារួម ឬគោលការណ៍អាជីវកម្មរបស់អ្នក ព្រមទាំងបញ្ជីអាហារសង្ខេបដែលអ្នកបម្រុងនឹងដាក់លក់ (250 ពាក្យ)

**ផ្នែកទី 3 ៖ គោលដៅសំខាន់ៗ**

យើងខ្ញុំចង់ដឹងអំពីសកម្មភាពជាក់លាក់ ដែលអ្នកសង្ឃឹមថានឹងសម្រេចបាន តាមរយៈគម្រោង និងបន្ទាត់ពេលវេលានេះ ។ សូមបំពេញតារាងខាងក្រោម ដើម្បីបង្ហាញអំពីគោលដៅ/បន្ទាត់ពេលវេលា/តួនាទីជាក់លាក់ ។

| **គោលដៅសំខាន់ដែលត្រូវរាយការណ៍ (ចំនួនទៅតាមអ្វីដែលអ្នកចង់បាន)** | **បន្ទាត់ពេលវេលា** (ការផ្ដួចផ្ដើម ដើម្បីសម្រេចគោលដៅ) | **បុគ្គលិកដឹកនាំសកម្មភាព** | **ដៃគូគាំទ្រ** |
|---|---|---|---|
| **គោលដៅទី 1៖** | | | |
| **គោលដៅទី 2:** | | | |

| **គោលដៅទី 3:** | | | |
|---|---|---|---|
| **គោលដៅទី 4៖** | | | |
| **គោលដៅទី 5:** | | | |
| **គោលដៅទី 6:** | | | |
| **គោលដៅទី 8:** | | | |
| **គោលដៅទី 9៖** | | | |
| **គោលដៅទី 10** | | | |

**ផ្នែកទី 4 ៖ ថវិកា**

1. **ថវិកា**

**សូមបង្ហាញគម្រោងថវិកាពេញលេញ ចំពោះសំណើសុំថវិការបស់អ្នក ដោយប្រើទម្រង់ឯកសារគំរូដូចខាងក្រោម ។** ***មិនជាបញ្ហាទេបើអ្នកត្រូវជ៉ាន់ស្មាន ឬទស្សន៍ទាយអំពីការចំណាយទាំងអស់នេះ ។*** *ផ្នែកណាដែលមិនពាក់ព័ន្ធ អាចរំលងចោលបាន ។ សូមរៀបរាប់លម្អិតពីការប្រើប្រាស់ថវិកាតាមផ្នែកនីមួយៗ ។ ឧទាហរណ៍ ក្រោមផ្នែកបុគ្គលិក អាចសរសេរ ៖ បុគ្គលិកពេញម៉ោងចំនួន 2 នាក់ ក្នុងតម្លៃ $15 ក្នុងមួយម៉ោង ចំនួនមួយឆ្នាំ ។ ក្រោមផ្នែកឧបករណ៍ អាចសរសេរ ទូរទឹកកកចំនួន 2 គ្រឿង ក្នុងតម្លៃ $1000 ក្នុងមួយគ្រឿង ។*

| **គម្រោងថវិកាសម្រាប់ថិរវេលាពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2020 – ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2021** | | |
|---|---|---|
| ប្រភេទថវិកា | ចំនួន $ | ការពណ៌នាអំពីថវិកា |
| បុគ្គលិក (មនុស្ស) | | |
| ថវិកាអត្ថប្រយោជន៍បន្ថែម | | |
| ទីប្រឹក្សា ឬអ្នកម៉ៅការបន្ត | | |
| ការធ្វើដំណើរ | | |
| ការផ្គត់ផ្គង់ | | |
| គ្រឿងសង្ហារិម/វត្ថុប្រើប្រាស់ផ្សេងៗ/ឧបករណ៍ | | |
| ការចំណាយរដ្ឋបាល | | |
| ផ្សេងៗ | | |
| **សរុប** | | |

កំណត់ចំណាំសម្រាប់ប្រភេទថវិកា ៖

1. ផ្នែកបុគ្គលិក

   a. បើត្រូវបើកប្រាក់ខែតាមតួនាទី សូមដាក់បញ្ចូលបុគ្គលិកម្នាក់ៗ ៖ បៀវត្សរ៍ (ក្នុងមួយឆ្នាំ ឬក្នុងមួយម៉ោង) ប្រាក់ឧបត្ថម្ភបន្ថែម (បើមានផ្តល់ជូន) ភាគរយនៃពេលវេលាចំណាយសម្រាប់គម្រោងនេះ តួនាទីរបស់បុគ្គលនោះ
   b. **សូមកត់ចំណាំថា ប្រាក់សម្រាប់ការរស់នៅ និងសំណងសមរម្យ គឺជាផ្នែកដ៏សំខាន់នៃគម្រោងនេះ។ សាលាក្រុង តម្រូវឲ្យអ្នកម៉ៅការ ត្រូវបង់ប្រាក់ឈ្នួលពលកម្មក្នុងកម្រិតអប្បរមាចំនួន $13.75/ម៉ោង សម្រាប់ប្រាក់ឈ្នួលពលកម្ម ដែលការលើកលែងមានកំណត់ ។**[5]

2. ទីប្រឹក្សា ឬអ្នកម៉ៅការបន្ត ៖ បើមានរួមបញ្ចូល សូមបន្ថែមបន្ទាត់មួយសម្រាប់អ្នកម៉ៅការម្នាក់ៗ រួចដាក់បញ្ចូលក្នុងការពណ៌នា អំពីតួនាទី/គោលដៅសម្រេចបាន ដែលពួកគេត្រូវធ្វើ ។
3. ការធ្វើដំណើរ ៖ បើជាការធ្វើដំណើរក្នុងតំបន់ សូមរៀបរាប់អំពីគោលបំណងនៃការធ្វើដំណើរ
4. ការផ្គត់ផ្គង់ ៖ សូមសរសេរចំណាំក្នុងការពណ៌នា ថាតើត្រូវការគ្រឿងផ្គត់ផ្គង់អ្វីខ្លះ ព្រមទាំងតម្លៃទូទៅក្នុងមួយមុខៗ
5. ចំណាយរដ្ឋបាល ៖ សូមសរសេរចំណាំក្នុងការពណ៌នាថា ថវិកាប្រភេទនេះ ត្រូវចំណាយលើអ្វីខ្លះ

2. សូមពណ៌នាដោយសង្ខេបអំពីការរៀបចំថវិកាដែលចេញជារូបរាងបែបនេះ (ដូចជាធ្វើឡើងដោយសំអាងលើការចំណាយដែលមានស្រាប់ ការសម្រង់តម្លៃ ការប៉ាន់ប្រមាណ ឬការប្រៀបធៀបជាមួយការចំណាយណាមួយ)

3. សូមពណ៌នាអំពីប្រភពផ្តល់ថវិកាបន្ថែមណាមួយ ដែលគម្រោងអ្នកអាចមាន (យើងមិនតម្រូវឲ្យមានមូលនិធិផ្គត់ផ្គង់ពីប្រភពផ្សេងឡើយ)

4. និរន្តរភាព ។ តើអ្នកត្រូវការធនធានផ្សេងទៀតអ្វីខ្លះ ដើម្បីទ្រទ្រង់គម្រោងនេះ ហើយតើអ្នកមានវិធីសាស្ត្របែបណា ដើម្បីទទួលបានធនធានទាំងអស់នោះ?

---

[5] https://www.phila.gov/ExecutiveOrders/Executive%20Orders/EO%203-14.pdf